ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១២៤៧ សហវ-អសហ

ភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០១៦

# ជម្រាបជូន

- ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- ឯកឧត្តមអគ្គាធិការ នៃអគ្គាធិការដ្ឋាន
- ឯកឧត្តមនាយក នៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**កម្មវត្ថុ:** ការផ្តល់កិច្ចសហការ និងការយកចិត្តទុកដាក់ចំពោះមុខងារសវនកម្មផ្ទៃក្នុង។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា អនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ជំពូកទី២ មាត្រា២ បានចែងថា "*ដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន សវនករផ្ទៃក្នុងត្រូវមានសិទ្ធិពេញលេញ សេរីភាពគ្រប់គ្រាន់ និងគ្មានការរារាំង ការហាមឃាត់ លើការចូលត្រួតពិនិត្យនូវគ្រប់សកម្មភាព រាល់បញ្ជីកត់ត្រា រាល់ទ្រព្យសម្បត្តិ និងបុគ្គលិករបស់អង្គភាព*"។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង សវនករផ្ទៃក្នុងនៅជួបការលំបាកខ្លះនៅឡើយពាក់ព័ន្ធនឹងការទទួលបានសិទ្ធិខាងលើ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ពិសេសទាក់ទងនឹងការផ្តល់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_abm@yhoo.com

ឯកសារ (រយៈពេលនិងភាពពេញលេញ) និងឱកាសពិភាក្សាជាមួយមន្ត្រីពាក់ព័ន្ធ ដោយសារមានករណីគេចវេះរបស់មន្ត្រីទទួលបន្ទុកមួយចំនួនជាបន្តបន្ទាប់ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងារសវនកម្មផ្ទៃក្នុង។

អាស្រ័យហេតុនេះ ក្នុងករណីសិទ្ធិខាងលើត្រូវបានបំពាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងកោះអញ្ជើញមន្ត្រីពាក់ពន្ធ័មកឆ្លើយបំភ្លឺ និងផ្តល់ព័ត៌មានរួមទាំងទិន្នន័យចាំបាច់ ជូនសវនករផ្ទៃក្នុងនៅអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងរហូតការងារបានបញ្ចប់។ ដោយឡែក អង្គភាពទាំងឡាយដែលត្រូវផ្តល់សេវាសាធារណៈផ្សេងទៀត ជូនដល់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក៏ត្រូវផ្តល់ជូនដោយការយកចិត្តទុកដាក់ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាបនិងចាត់ចែងបន្តតាមការគួរ។

សូមឯកឧត្តមទទួលនូវការរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**